# កម្មវិធី WorkFirst

ការជួយលាកអ្នក ការជួយខ្លួនលោកអ្នក និងគ្រួសារលោកអ្នក។



Washington State
Department of Social
& Health Services

*Transforming lives*

WASHINGTON
WorkFirst

# សេវាកម្មកម្មវិធី WorkFirst

សេវាកម្មកម្មវិធី WorkFirst អាចជួយអ្នកតាមរយៈស្ថានភាពបណ្តោះអាសន្នរបស់លោកអ្នក។
យើងនៅទីនេះដើម្បីជួយអ្នកអោយមានការងារធ្វើ និងរក្សា វាអោយបាន។ យើងអាចជួយអ្នករកការងារធ្វើបាន:

- ជំនាញការងារ សមត្ថភាព និងការងារអ្វីដែលអ្នកចាប់អារម្មណ៍ចង់ធ្វើ
- ការងារដែលមាននៅក្នុងស្រុករបស់លោកអ្នក

# ឱកាសការងារពីកម្មវិធី WorkFirst

**តើលោកអ្នកចង់រកចំណូលសំរាប់ជីវភាពរស់នៅរបស់ក្រុមគ្រួសារលោកអ្នកដែរឬទេ?**
កម្មវិធី WorkFirst អាចជួយលោកអ្នករកប្រាក់ចំណូលគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់កូន របស់លោកអ្នក ។
យើងមានឱកាសការងារជាច្រើនដូចជា:

- ជួយស្វែងរកការងារធ្វើ
- ធ្វើការបណ្តុះបណ្តាល និងការអប់រំ
- កម្មវិធីបទពិសោធន៍ការងារ
- ជួយបំពេញការចំណាយលើការងារដូចជា ការធ្វើដំណើរ និងការថែទាំកូន



# ប្រាក់បៀវត្សន៍បានពីការងារ!

**ការងារតែងតែល្អប្រសើរជាងប្រាក់បានពីសុខុមាលភាពសង្គម។**

នៅពេលដែលលោកអ្នកត្រឡប់មកផ្ទះវិញដោយនាំមកនូវ មូលប្បទានប័ត្រទូទាត់ប្រាក់
លោកអ្នកអាចទិញបានរបស់របរជាច្រើនសម្រាប់គ្រួសាររបស់អ្នក!

| ប្រាក់សុខុមាលភាពសង្គម | មូលប្បទានប័ត្រទូទាត់ប្រាក់ |
|---|---|
| $706.00 ដុល្លា ក្នុងមួយខែ* | $2,800.00 ដុល្លា ក្នុងមួយខែ<br>($16.28 ដុល្លា ក្នុងមួយម៉ោងធ្វើការ 40 ម៉ោងមួយអាទិត្យ)** |

* TANF ផ្តល់ឱ្យសម្រាប់គ្រួសារដែលមានសមាជិកបីនាក់

**ផ្អែកលើប្រាក់ឈ្នួលអប្បបរមារបស់រដ្ឋ ចាប់ពីខែមករា ឆ្នាំ 2024

# ការវាយតម្លៃគ្រប់ជ្រុងជ្រោយ

**ទទួលបានការវាយតម្លៃគ្រប់ជ្រុងជ្រោយដែលផ្តោតលើគ្រួសារដែលនឹងត្រូវជួយលោកអ្នក:**

- ធ្វើការកំណត់សំគាល់សេវាកម្ម និងសកម្មភាពនានាដែលនឹងត្រូវជួយ អោយលោកអ្នក ឈានទៅដល់ការឈោងចាប់យកគោលដៅការងាររបស់លោកអ្នក ។
- ពិនិត្យវិនិច្ឆ័យទៅលើការអប់រំ និងវគ្គបណ្តុះបណ្តាលដែលលោកអ្នកត្រូវការ និងចាប់អារម្មណ៍ ។
- ធ្វើការកំណត់សំគាល់ពីជំនាញ និងភាពខ្លាំងរបស់លោកអ្នក ។
- ដោះស្រាយរាល់បញ្ហាឧបសគ្គដែលសមត្ថភាពរបស់លោកអ្នកអាចនៅមានដែនកំណត់នៅឡើយ ទាំងការស្វែងរកការងារធ្វើ ឬការត្រៀមលក្ខណៈដើម្បីធ្វើការ ។
- អភិវឌ្ឍផែនការងារងាររយៈពេលខ្លី - និងរយៈពេលវែង ។



# ការផ្តាច់ផ្ការយល់ព្រម

កម្មវិធី WorkFirst ផ្តល់ការជួយទំនុកបំរុង និងសេវាកម្មច្រើនទៅដល់អ្នកតាមរយៈ ស្ថានភាពបណ្តោះអាសន្នរបស់លោកអ្នក។ លោកអ្នកត្រូវតែចូលរួមនៅក្នុងកម្មវិធី ហើយទទួលផលប្រយោជន៍នៃការជួយទំនុកបំរុងដែលបង្កើតឡើង ដើម្បីជួយលោកអ្នកស្វែងរក និងរក្សាការងារអោយបាន។ បើលោកអ្នកមិនជ្រើសរើសចូលរួមនោះទេ លោកអ្នកនឹងប្រឈមមុខទៅនឹង ការបាត់បង់ប្រាក់ឧបត្ថមរបស់លោកអ្នក ។

យើងខ្ញុំចង់ជួយលោកអ្នកកសាងផែនការអោយល្អប្រសើរឡើងសំរាប់លោកអ្នកកូនរបស់លោកអ្នក ប៉ុន្តែលោកអ្នកត្រូវតែខិតខំធ្វើការងារដែលជាចំណែករបស់អ្នកផង។



# ការជួយស្វែងរកការងារធ្វើ

**បុគ្គលិកដែលមានជំនាញខាងសេវាកម្មរកការងារធ្វើនឹងធ្វើការជាមួយលោកអ្នក:**

- ស្វែងរកអោយឃើញនូវពត្តមានដែលមានតម្លៃអំពីចំណាប់អារម្មណ៍ និងជំនាញការងារ។
- ធ្វើប្រវត្តិរូបការងារដែលអាចទទួលបានលទ្ធផល ។
- ទទួលបានការអនុវត្តន៍លើបច្ចេកទេសសំភាសន៍ ។
- និយោជកក្នុងនៅតំបន់និងជួលអោយធ្វើការ ។
- ភ្ជាប់ទំនាក់ទំនងលោកអ្នកជាមួយនឹងការងារដែលមានប្រាក់បៀវត្តន៍ខ្ពស់ដែលត្រូវនឹង សមត្ថភាពរបស់អ្នក ។
- មានអារម្មណ៍ថាមានទំនុកចិត្តនៅពេលអ្នកជួប និងធ្វើការជាមួយនិយោជក។

# ឱកាសការអប់រំ និងវគ្គបណ្តុះបណ្តាលជាច្រើន

**ការបើកទ្វារទៅរកការរីកចំរើនលើការងារ និងមុខរបរ និង *រកប្រាក់អោយ បានច្រើនថែមទៀត ។***

- យ៉ាងហោចណាស់បញ្ចប់វិទ្យាល័យ ឬបានបញ្ចប់ប្រហាក់ប្រហែលវិទ្យាល័យ។
- ធ្វើអោយភាសារអង់គ្លេសរបស់លោកអ្នកបានប្រសើរឡើងទាំងការអាន ការសរសេរ និងគណិតវិទ្យាដែលស្ថិតក្នុងកំរិតការអប់រំមូលដ្ឋានសំរាប់មនុស្សពេញវ័យ (ABE) ឬថ្នាក់ភាសាអង់គ្លេសជាភាសាទីពីរ (ESL) ។
- រៀនជំនាញភាសាអង់ថ្មីនៅក្នុងបែបវិជ្ជាជីវៈ បច្ចេកទេស ឬកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ។
- រៀនអំពីជំនួយការហិរញ្ញវត្ថុ និងសេវាកម្មជួយផ្គត់ផ្គង់សិស្ស ។

# បទពិសោធន៏ការងារ

**មានកម្មវិធីបទពិសោធន៏ការងារមួយចំនួនដែលអាចផ្តល់ឱកាសជូនលោក អ្នកដែរ :**

- ទទួលបានជំនាញការងារដែលមានតម្លៃនៅកន្លែងការងារ ។
- អភិវឌ្ឍន៏ជំនាញការងារដើម្បីរៀបចំលោកអ្នកសំរាប់ការងារនាយពេលអនាគត ។
- ជួយអ្នកគ្រប់គ្រងអោយបានល្អប្រសើរនូវការប្រឈមមុខនៅក្នុងជីវិតរបស់អ្នក។
- ចូលរួមនៅក្នុងឱកាសវគ្គបណ្តុះបណ្តាល និងការអប់រំនៅខណៈពេលកំពុងធ្វើការ ។
- ឧបករណ៏អនុវត្តន៏ដែលនឹងជួយលោកអ្នក និងគ្រួសាររបស់លោកអ្នកអោយចាកចេញ ពីការទទួលបាន TANF ។
- ធ្វើការទំនាក់ទំនងជាមួយនិយោជក និងកសាងអោយបានអ្នកធានាការងារ។



# ការថែទាំកុមារ

- យើងខ្ញុំអាចជួយបង់ប្រាក់សំរាប់ការថែរក្សាកុមារ នៅខណៈដែលលោកអ្នកធ្វើការ ឬ ឧបមាដូចជាទៅសាលារៀន ។
- បើសិនទទួលបានសិទ្ធស្របច្បាប់ លោកអ្នកគ្រាន់តែចំណាយលើផ្នែកថ្លៃការថែទាំកុមារសំរាប់គ្រួសារមួយចំនួន វាចំណាយបន្តិចបន្តួចដូចជា $0 ដុល្លា។
- មានប្រភេទពិបាកមួយចំនួននៃអ្នកផ្គត់ផ្គងការថែទាំកុមារ ដើម្បីជ្រើសរើសមក។

**សំរាប់ជួយស្វែងរកអ្នកផ្គត់ផ្គងការថែទាំកុមារដែលមានអជ្ញាប័ណ្ណ**
**សូមទូរសព្ទទៅកាន់កម្មវិធីការលើកកម្ពស់ការថែទាំកុមារនៅ :**

**1-844-626-8687**

# ការផ្គត់ផ្គងការងារ

**កម្មវិធីសេវាកម្មជួយផ្គត់ផ្គង់ WorkFirst ជួយចំណាយលើអ្វីដែល លោកត្រូវការធ្វើការស្វែងរកការងារធ្វើ ឬត្រៀមលក្ខណៈដើម្បីធ្វើការ ។**

**សេវាកម្មជួយផ្គត់ផ្គង់អាចរួមមានទាំង :**

- សំបុត្រឡើងជិះឡានក្រុង
- ការសម្ភាសន៍ និងសំលៀកបំពាក់ធ្វើការ
- ការជួសជុលឡាន
- ការផ្តល់ប្រឹក្សា
- កន្ទប
- ការចំណាយលើការអប់រំ
- អនាម័យផ្ទាល់ខ្លួន
- អាជ្ញាប័ណ្ណ / តម្លៃ
- កាត់សក់
- ឧបករណ៍ និងសម្ភារ:
- ផែនការគ្រួសារ
- រយៈចម្ងាយនៃឧស្ម័ន

# ពត៌មានផែនការគ្រួសារ

**សូមចាប់ផ្តើមនិយាយអំពីហេតុអ្វីផែនការគ្រួសារមានសារៈសំខាន់!**

លោកអ្នកអាចសម្រេចចិត្តនៅពេលដែលអ្នកត្រៀមខ្លួនរួចរាល់ដើម្បីមានកូនមួយទៀត។ ផែនការគ្រួសារអោយលោកអ្នកនូវជំរើស  និងការគ្រប់គ្រងលើហិរញ្ញវត្ថុរបស់ លោកអ្នកនាពេលអនាគត ។

- សំរាប់ពត៌មានបន្ថែម លោកអ្នកអាចទាក់ទងទៅការិយាល័យវេជ្ជបណ្ឌិតរបស់ លោកអ្នក កន្លែងលក់ឱសថស្ថាន ឬអ្នកផ្តត់ផ្គង់សេវាផែនការគ្រួសារ។
- ពួកគាត់អាចពន្យល់ពីអ្វីដែលជាវិធីសាស្រ្តផែនការគ្រួសារអាចមាន ដូច្នេះលោកអាចសំរេចចិត្តថាត្រូវធ្វើអ្វីដែលល្អបំផុតសំរាប់លោកអ្នក ។
- កាតសេវាកម្មសុខុមាលភាពសង្គមរបស់លោកអ្នកបង់សំរាប់ថ្លៃវេជ្ជបញ្ជាទិញថ្នាំកុំអោយមានកូន ការសង្រ្គោះបន្ទាន់កុំអោយមានកូន និងវិធីសាស្រ្តមួយចំនួនទៀតដែលមិនបានរៀបរាប់ពីតំលៃ។

# ការធានារ៉ាប់រងការថែទាំសុខភាព

**ប្រសិនបើអ្នកមិនមានការធានារ៉ាប់រងការថែទាំសុខភាព លោកអ្នក អាចដាក់ពាក្យ ស្នើសុំពីកម្មវិធី Washington Healthplanfinder ដោយ:**

- ទូរសព្ទទៅលេខ 1-855-923-4633 ឬ
- បំពេញពាក្យស្នើសុំតាមអនឡាញនៅលើគេហទំព័រ www.wahealthplanfinder.org ឬ
- យកពាក្យស្នើសុំដែលបំពេញរួច ទៅដាក់នៅក្រសួងក្នុងតំបន់ DSHS នៅការិយាល័យសេវាកម្មសហគមន៍ (CSO) ។



# ការផ្តត់ផ្គង់កុមារ

**ការផ្តត់ផ្គង់កុមារអាចៈ**

- បានប្រមូលកូនដែលមិនរស់នៅជាមួយឪពុកម្តាយ។
- ជួយលោកអ្នកអោយរស់នៅដោយឯករាជ្យ ។
- ជួយកូនរបស់លោកអ្នកអោយមានជីវិតរស់នៅបានល្អប្រសើរ។
- ផ្តល់អោយលោកមានលុយថែមទៀតសំរាប់សំល្បេកបំពាក់ អាហារ និង អ្វីៗដែល សំខាន់ថែមទៀត។

**សូមនិយាយជាមួយមន្ត្រីប្រតិបត្តលើការជួយផ្តត់ផ្គង់**
**បើលោកអ្នកមានសំណួរអ្វី ឬសូមទូរសព្ទ :**

# 1-800-442-KIDS

## (1-800-442-5437)

# ពត៌មានទាក់ទងនឹងអំពើហឹង្សាក្នុងគ្រួសារ

- តើមានអ្នកណាម្នាក់វាយធ្វើបាបអ្នក ឬអ្នកមានការឈឺចាប់?
- តើអ្នកចង់អោយមានការជួយដោះស្រាយចំពោះអ្នកដែលគំរាមគំហែង ឬព្យាយាមធ្វើ បាបអ្នកដែរឬទេ?
- តើអ្នកកំពុងតែមានការបារម្ភណ៍ថា ការចូលរួមនៅក្នុងសកម្មភាពកម្មវិធី WorkFirst តាមធម្មតា ឬ ការប្រមូលការជួយផ្តត់ផ្គង់កុមារអាចមានគ្រោះថ្នាក់ ឬធ្វើអោយអ្វីៗកាន់ តែពិបាកថែមទៀតសំរាប់លោកអ្នក ឬកូនរបស់លោកអ្នក?

បើដូច្នេះមែន យើងអាចណែនាំលោកអ្នកទៅកាន់មនុស្សផ្សេងទៀត ជាអ្នកដែលអាច ជួយលោកអ្នករៀបចំផែនការសំរាប់សុវត្ថិភាពរបស់លោកអ្នក បន្តផ្តល់នូវការជួយផ្តត់ ផ្គង់ផ្លូវអារម្មណ៍ និងភ្ជាប់លោកអ្នកទៅនឹងធនធានដែលមានប្រយោជន៍ផ្សេងទៀត។

យើងខ្ញុំប្រហែលអាចជួយលោកអ្នកបានបណ្តោះអាសន្នពីសកម្មភាពការងារ និងការ ប្រមូលការជួយផ្តត់ផ្គង់កុមារ - សំរាប់ពត្តមានបន្ថែមទៀតសូមនិយាយជាមួយប្រធាន គ្រប់គ្រងករណីរឿង ក្នុងក្រសួង DSHS របស់លោកអ្នក។

**លោកអ្នកក៏ប្រហែលជាអាចទាក់ទងបន្ទាន់ទៅកម្មវិធីអំពើហឹង្សាក្នុងគ្រួសារ Domestic Violence Hotline តាមលេខទូរសព្ទហតឡាញ 1-800-799-7233**

**សំរាប់ពត៌មានបន្ថែមដោយយោងទៅលើ និងការជួយផ្តត់ ផ្គង់។ ការទូរសព្ទហតឡាញមិនគិតថ្លៃនោះទេ ហើយមានទំនុកចិត្ត។**

# ការចាកចេញពី កម្មវិធី WorkFirst?

## លោកអ្នកអាចទទួលបានជំនួយនៅពេលដែលលោកអ្នកចាកចេញពីកម្មវិធី WorkFirst

### សេវាគាំទ្រ

- អ្នកអាចមានសិទ្ធិទទួលបានជំនួយដែលទាក់ទងនឹងមធ្យោបាយដឹកជញ្ជូន ដូចជាហ្គាស ប័ណ្ណឡើងជិះឡានក្រុង និងការជួសជុលរថយន្ត រយៈពេលរហូតដល់ 5 ខែ។

### ជំនួយស្បៀងអាហារដែលជាអន្តរកាល

- លោកអ្នកប្រហែលជាអាចទទួលបានសិទ្ធសំរាប់បន្តទទួលបានអត្ថប្រយោជន៍ម្ហូបអាហារ រហូតទៅដល់ 5 ខែ។ បន្ទាប់ពីទទួលបានអត្ថប្រយោជន៍ម្ហូបអាហារ នោះអាស្រ័យទៅ លើចំណូលនៃការចំណាយលើការរស់នៅ និងទំហំផ្ទះ។

### ការធានារ៉ាប់រងការថែទាំសុខភាព

- លោកអ្នកប្រហែលជាអាចមានលក្ខណ:សម្បត្តិគ្រប់គ្រាន់សំរាប់ការធានារ៉ាប់រងការ ថែទាំសុខភាព បើទោះបីជាលោកអ្នកលែងទទួលបានជំនួយពីកម្មវិធី TANF

### ស្បៀងអាហារជាមូលដ្ឋានសំរាប់វគ្គបណ្តុះបណ្តាល និងការងារ

- បើលោកអ្នកទទួលបានម្ហូបអាហារជាមូលដ្ឋាន នោះលោកអ្នកអាចមានលទ្ធភាពស្វែងរកការងារ ស្វែងរកការបណ្តុះបណ្តាលពីការងារ សេវាកម្មអប់រំ វគ្គបណ្តុះបណ្តាលពី ជំនាញ កន្លែងផ្តល់សេវាកម្មតាមសហគមន៍ សេវាជួយផ្គត់ផ្គង់ក្រោយពេលបានការងារ ធ្វើ និងឱកាសការងារផ្សេងៗទៀត។ ប្រសិនបើលោកអ្នកបានចូលរួមក្នុងសហគមន៍ ឬ មហាវិទ្យាល័យបច្ចេកទេសរួចហើយនោះ ការធ្វើការផ្លាស់ប្តូរដើម្បីទទួលបានស្បៀង អាហារជាមូលដ្ឋានសំរាប់វគ្គបណ្តុះបណ្តាល និងការងារអាចជួយលោកអ្នកបំពេញគោលដៅការអប់រំរបស់លោកអ្នក។ សំរាប់ពត៌មានបន្ថែមសូមទាក់ទងការិយាល័យមហាវិទ្យាល័យ BFET របស់លោកអ្នក ឬចូលទៅកាន់គេហទំព័រ https://www.dshs.wa.gov/esa/community-partnership-program/basic-food-employment-training-bfet

### ផ្ទះ HUD

- ជួយស្វែងរកផ្ទះដែលមានតំលៃទាប ទៅកាន់ www.hud.gov

### ការប្រមូលការជួយផ្គត់ផ្គង់កុមារ

- យើងនៅតែប្រមូលការជួយផ្គត់ផ្គង់កុមារ ប៉ុន្តែឥឡូវវាទៅដល់អ្នកហើយ!

### ការថែទាំកុមារ

- លោកអ្នកប្រហែលនៅតែអាចទទួលបានការថែទាំកុមារ ប្រសិនបើលោកអ្នកធ្វើការ

### ការជួយស្វែងរកការងារធ្វើអោយបានល្អប្រសើរ

- ទៅកាន់ការិយាល័យប្រភាពការងារ WorkSource ណាមួយ។ លោកអ្នកក៏អាចទៅរកការិយាល័យណាមួយដែលនៅជិតបំផុត ហើយសំរាប់ការស្វែងរកការងារសូមចូលទៅកាន់គេហទំព័រ WorkSourceWA.com

# ការចាកចេញពី កម្មវិធី WorkFirst? បន្ត ...

### ឥណទានពន្ធលើប្រាក់ចំណូលដែលរកបាន (EITC)

- ការបែងចែកមើលពន្ធសំរាប់គ្រួសារដែលធ្វើការងារបានប្រាក់ចំណូលទាប : សូមមើល គេហទំព័រ EITC: www.irs.gov/ ហើយស្វែងរក EITC ។

### កម្មវិធី LIHEAP

- ការជួយបង់ប្រាក់ថ្លៃធ្វើអោយផ្ទះរបស់លោកអ្នកមានកំដៅ និងត្រជាក់ សូមចូលទៅកាន់ គេហទំព័ររបស់កម្មវិធី LIHEAP : www.commerce.wa.gov ហើយស្វែងរក LIHEAP ។

# ធនធានក្នុងស្រុក

គេហទំព័រកម្មវិធី **WorkFirst:**

**www.workfirst.wa.gov/**

បណ្តាញណពត៌មានរដ្ឋវ៉ាស៊ីនតោន **211**:

**http://win211.org**

ការភ្ជាប់ទៅកាន់រដ្ឋវ៉ាស៊ីនតោន

**http://washingtonconnection.org**

- ធនាគារស្បៀងអាហារក្នុងស្រុក
- ការភ្ជាប់ក្នុងស្រុក
- គ្លីនិកសេវាកម្មវេជ្ជសាស្ត្រក្នុងស្រុក
- ការជួយផ្គត់ផ្គង់កុមារ និងធនធានក្នុងស្រុក
- ផ្ទះសំបែង

បើសិនលោកអ្នកមានសំណួរអ្វី ឬត្រូវការពត្ថមានបន្ថែមទៀត
សូមទាក់ទងការិយាល័យ **CSO** របស់លោកអ្នក ឬទាក់ទងទៅមជ្ឈមណ្ឌល។

Washington State
Department of Social
& Health Services

*Transforming lives*

DSHS 22-1125 CA (Rev. 1/24) Cambodian